ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករធានារ៉ាប់រងកម្ពុជា
លេខ.០៤១............ន.ធ.ក./សណាន

# សេចក្តីណែនាំ
# ស្តីពី
# ពិពិធកម្មនៃការធានារ៉ាប់រងបន្ត

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង និងប្រកាសលេខ ០៤៤ អ.ស.ហ.ប្រក ចុះថ្ងៃទី១២ ខែកក្កដា គ.ស.២០២៤ ស្តីពីវិធាន និងគោលការណ៍ណែនាំស្តីពីការធានារ៉ាប់រងបន្ត ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធការធានារ៉ាប់រង **និយ័តករធានារ៉ាប់រងកម្ពុជា** (**ន.ធ.ក.**) សូមចេញសេចក្តីណែនាំស្តីពី "**ពិពិធកម្មនៃការធានារ៉ាប់រងបន្ត**" ក្នុងគោលបំណងធានានូវសុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការការពារហានិភ័យរបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលមានកំណត់ដូចខាងក្រោម៖

## ១) ពិពិធកម្មនៃការធានារ៉ាប់រងបន្ត

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្ទេរហានិភ័យដែលលើសពីកម្រិតរក្សាទុកហានិភ័យ ទៅក្រុមហ៊ុនធានារ៉ាប់រងបន្តក្រៅប្រទេស តាមលក្ខខណ្ឌ ដូចខាងក្រោម៖

<table>
<tr><th colspan="4">ចំណាត់ថ្នាក់ឥណទាន ឬ<br>ចំណាត់ថ្នាក់ឥណទានសមមូល</th><th colspan="2">កម្រិតអតិបរមានៃការផ្ទេរហានិភ័យក្នុងមួយកិច្ចព្រមព្រៀង</th></tr>
<tr><th>Standard & Poor</th><th>Moody</th><th>AM Best</th><th>Fitch</th><th>ការធានារ៉ាប់រងទូទៅ</th><th>ការធានារ៉ាប់រងអាយុជីវិត</th></tr>
<tr><td>AAA</td><td>Aaa</td><td>A++</td><td>AAA</td><td rowspan="3">• ៥០% សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងបន្តនាំមុខ<br>• ១៥% សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងបន្តចូលរួមនីមួយៗ</td><td rowspan="3">១០០%</td></tr>
<tr><td>AA+<br>AA<br>AA-</td><td>Aa1<br>Aa2<br>Aa3</td><td>A+</td><td>AA+<br>AA<br>AA-</td></tr>
<tr><td>A+<br>A<br>A-</td><td>A1<br>A2<br>A3</td><td>A<br>A-</td><td>A+<br>A<br>A-</td></tr>
<tr><td>BBB+<br>BBB</td><td>Baa1<br>Baa2</td><td>B++<br>B+</td><td>BBB+<br>BBB</td><td>១០% សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងបន្តចូលរួមនីមួយៗ</td><td>៦០%</td></tr>
</table>

២) **ការអនុវត្តនៃសេចក្តីណែនាំ**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវប្រើប្រាស់ចំណាត់ថ្នាក់ឥណទានដែលទាបជាងគេ ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងបន្តក្រៅប្រទេសទទួលបានចំណាត់ថ្នាក់ឥណទានលើសពីមួយ ដែលមានកម្រិតចំណាត់ថ្នាក់ផ្សេងគ្នា ។

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ក.** លើការផ្លាស់ប្តូរ ឬរក្សាទុកក្រុមហ៊ុន-ធានារ៉ាប់រងបន្តក្រៅប្រទេស ក្នុងករណីចំណាត់ថ្នាក់ឥណទានរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តក្រៅប្រទេសនោះ ធ្លាក់ចុះក្រោមកម្រិតអប្បបរមា ដូចមានកំណត់ក្នុងសេចក្តីណែនាំនេះ ក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់) ថ្ងៃ បន្ទាប់ពីទទួលបានព័ត៌មានអំពីការធ្លាក់ចុះ។

ក្រុមហ៊ុនធានារ៉ាប់រងណាដែលមិនគោរពតាមសេចក្តីណែនាំនេះត្រូវទទួលទោស ដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣) **សុពលភាពនៃសេចក្តីណែនាំ**

ទទួលបានសេចក្តីណែនាំនេះ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ២ កើត ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ សីហា គ.ស.២០២៤

**អគ្គនាយក**
**និយ័តករធានារ៉ាប់រងកម្ពុជា**

**ប៊ូ ច័ន្ទភិរុ**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ឯកសារ-កាលប្បវត្តិ